# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៨៥ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃសាលាវិជ្ជាជីវៈទេសចរណ៍

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ._**

ត្រូវបានបង្កើតសាលាវិជ្ជាជីវៈទេសចរណ៍ ដែលសរសេរជាអក្សរកាត់ថា "**ស.វ.ទ.**" និងជាភាសាអង់គ្លេស "Vocational School of Tourism" ដែលសរសេរជាអក្សរកាត់ថា "V. S.T." ។

**មាត្រា ២ ._**

**ស.វ.ទ.** ត្រូវបានកំណត់ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានឧបនិស្ស័យជាស្ថាប័នអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍និងមានស្វ័យភាពបរិបូរណ៍ក្នុងការដឹកនាំ និងគ្រប់គ្រងសកម្មភាពរបស់ខ្លួន។

**ស.វ.ទ.** គឺជានីតិបុគ្គលនៃនីតិសាធារណៈដែលមានស្វ័យភាពហិរញ្ញវត្ថុ។

**មាត្រា ៣ ._**

**ស.វ.ទ.** ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងទេសចរណ៍ និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៤ ._**

**ស.វ.ទ.** មានស្នាក់ការស្ថិតនៅក្នុងតំបន់កាំកូស៊ីធី ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងអាចមានសាខាតាមការចាំបាច់។

## ជំពូកទី២

## បេសកកម្ម តួនាទីនិងភារកិច្ច

**មាត្រា ៥ ._**

បេសកកម្មរបស់ **ស.វ.ទ.** គឺធ្វើការបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពអ្នកជំនាញទេសចរណ៍កម្ពុជាស្របតាមស្តង់ដាជាតិនិងអន្តរជាតិ ។

**មាត្រា ៦ ._**

**ស.វ.ទ.** មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- អប់រំបណ្តុះបណ្តាលអ្នកជំនាញឯកទេសវិជ្ជាជីវៈផ្នែកទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ចគ្រប់កម្រិត សំដៅបម្រើឱ្យឧស្សាហកម្មទេសចរណ៍
- រៀបចំលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ ស.វ.ទ.

- រៀបចំកម្មវិធីសិក្សា គរុកោសល្យ និងឯកសារបច្ចេកទេសវិទ្យាសាស្ត្រជំនាញទេសចរណ៍ជាភាសាខ្មែរ និងភាសាបរទេសឱ្យបានសមស្របដោយអនុលោមតាមស្តង់ដាបណ្តុះបណ្តាលអប្បរមាជាតិ និង អន្តរជាតិ
- អប់រំបណ្តុះបណ្តាលអ្នកឯកទេសវិជ្ជាជីវៈផ្នែកទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច
- បង្កើនសមត្ថភាពជំនាញបច្ចេកទេសដល់គ្រូបង្រៀន សាស្ត្រាចារ្យ សម្រាប់ការបណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈទេសចរណ៍
- រួមចំណែករៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់វិស័យទេសចរណ៍នៅក្នុងប្រទេស
- រៀបចំការជ្រើសរើសសិស្ស និស្សិតឱ្យចូលរៀន និងការប្រឡងបញ្ចប់ដោយវាយតម្លៃការសិក្សាឱ្យ បានត្រឹមត្រូវប្រកបដោយតម្លាភាព
- ផ្តល់វិញ្ញាបនបត្រ សញ្ញាបត្រ និងលិខិតបញ្ជាក់បច្ចេកទេសវិជ្ជាជីវៈទេសចរណ៍
- រៀបចំគម្រោងផែនការអភិវឌ្ឍន៍ ស.វ.ទ. ឱ្យបានសមស្របទៅតាមតម្រូវការទីផ្សារការងារក្នុងវិស័យ ទេសចរណ៍ទាំងក្នុង និងក្រៅប្រទេស
- ធ្វើទំនាក់ទំនងនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជននិងដៃគូអភិវឌ្ឍនានាទាំងក្នុងនិងក្រៅប្រទេស សាកលវិទ្យាល័យ វិទ្យាស្ថានក្នុងនិងក្រៅប្រទេស និងអង្គការជាតិ អន្តរជាតិ ដើម្បីស្វែងរក ដៃគូចូលរួមសហការសំដៅធ្វើឱ្យកាន់តែល្អប្រសើរឡើងនូវការគាំទ្រផ្នែកហិរញ្ញវត្ថុ ការផ្លាស់ប្តូរ ព័ត៌មាន និងបទពិសោធន៍ ការសិក្សាស្រាវជ្រាវ វិទ្យាសាស្ត្រ បច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងផ្តល់ជំនាញប្រកបដោយគុណភាព
- គ្រប់គ្រងមន្ត្រីរាជការ កម្មករ និយោជិត សិស្ស និស្សិត គ្រូបង្រៀន សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិរបស់ **ស.វ.ទ.**។

## **ជំពូកទី៣**
## **ក្រុមប្រឹក្សាភិបាល និងអង្គភាពប្រតិបត្តិ**

### **ផ្នែកទី១**
### **ក្រុមប្រឹក្សាភិបាល**

**មាត្រា ៧ ._**

**ស.វ.ទ.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសិទ្ធិយ៉ាងទូលំទូលាយក្នុងការចាត់ចែងការងារ ប្រកបដោយស្វ័យភាពបរិបូរណ៍ក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនានានៃអនុក្រឹត្យនេះ និងតាមបទបញ្ជាផ្ទៃក្នុង របស់ **ស.វ.ទ.** ។

**មាត្រា ៨ ._**

ក្រុមប្រឹក្សាភិបាលមានសមាជិក ០៩ (ប្រាំបួន) រូប ដែលមានសមាសភាពដូចតទៅ